ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០២១/១៤ - វីកកូ ហ៊ែនប៊ែក ខេមបូឌា អ៊ិនដាសស្ទ្រៀល
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ញាន សុមុន្និទ្ធ**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន វីកកូ ហ៊ែនប៊ែក (ខេមបូឌា) អ៊ិនដាសស្ទ្រៀល**

អាសយដ្ឋាន ៖ ភូមិត្រពាំងវែង និងធ្លក ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

ទូរស័ព្ទ ៖ ០១២ ៦៦៧ ៤៦៧ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

១- លោកស្រី អ៊ុំ ណាវី ប្រធានរដ្ឋបាល

២- លោក ជា សុខទ្រី រដ្ឋបាល

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - **សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា**

អាសយដ្ឋាន ៖ ផ្ទះលេខ១៦ ផ្លូវ៣៧៦ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន ភ្នំពេញ

ទូរស័ព្ទ ៖ ០១៧ ៥៥២ ៤៥២ ទូរសារ ៖ គ្មាន

ភាគីកម្មករនិយោជិត ៖

១- លោក តាត់ គីមឈិន កម្មករ

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ស្នើសុំឱ្យក្រុមហ៊ុនដំឡើងប្រាក់ខែចំនួន ១៦០ ដុល្លារ ក្នុងមួយខែ ។

២- សុំឱ្យក្រុមហ៊ុនទទួលយកកម្មករឈ្មោះ គាត់ គីមឈិន ផ្នែកតុកាត់ អត្តលេខ ០៨៣០ ចូលធ្វើការកន្លែងដើមវិញ ។

៣- ស្នើមិនឱ្យក្រុមហ៊ុនកាត់លុយកម្មករឈប់ឈឺមានសំបុត្រពេទ្យ ។

៤- ស្នើឱ្យមានទារកដ្ឋានសម្រាប់កម្មករ ។

៥- ស្នើសុំលុយបាយថ្ងៃត្រង់ ១៥ ដុល្លារ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៩៥ កប/ប្រក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ (អាណត្តិទី១១) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីពីលទ្ធផលនៃការដោះស្រាយវិវាទរួមនៅក្រុមហ៊ុន វីកកូ ហ៊ែនប៉ែក ខេមបូឌា អ៊ិនដាសស្ទ្រៀល លេខ ០៨២/១៤ របក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៤ ។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ " ។

**កាលបរិច្ឆេទសវនាការ** ៖ - ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ (វេលាម៉ោង ១៤ និង ០០ នាទី រសៀល ) ។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ស្ពឺ បានទទួលបណ្តឹងមួយច្បាប់របស់សហជីពសេរីកម្មករ ស្តីពីសំណើសុំឱ្យលោកនាយក ជួយដោះស្រាយនូវបញ្ហាចំនួន ០៥ ចំណុច ។ ក្រោយទទួលបានពាក្យបណ្តឹងរួច លោកប្រធានមន្ទីរការងារខេត្ត បានចាត់តាំងឱ្យអ្នកផ្សះផ្សាធ្វើការអញ្ជើញភាគីទាំងពីរមកសាកសួរព័ត៌មាន និងធ្វើការផ្សះផ្សាវិវាទទាំង ៥ ចំណុចនោះ ។ បន្ទាប់មកនៅថ្ងៃទី២២ ខែមករា ឆ្នាំ ២០១៤ អ្នកផ្សះផ្សាបានអញ្ជើញភាគីទាំងពីរមកធ្វើការសាកសួរព័ត៌មាននៅមន្ទីរការងារ និងធ្វើការផ្សះផ្សា នៅវេលា

ម៉ោង ០២៖០០ រសៀល ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤។ ជាលទ្ធផល ភាគីទាំងពីរនៅតែមិនអាចសះជាគ្នាបានឡើយ។ ចំណុចមិនសះជា ចំនួន ០៥ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៤ តាមរយៈរបាយការណ៍ស្តីពី ការដោះស្រាយវិវាទការងាររួម លេខ ០៨២/១៤ របក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ ២០១៤។

បន្ទាប់ពីបានទទួលសំណុំរឿងនេះមក ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ ២០១៣។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៥ ចំណុចនេះ នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ វេលាម៉ោង ០២៖០០ នាទី រសៀល។ ភាគីទាំងនិយោជក និង លោក ឃុត ថេត និងកម្មករឈ្មោះ តាក់ គីមឈិន (ដែលបានអះអាងថា ពួកគាត់តំណាងភាគីកម្មករនិយោជិត) មានវត្តមាននៅថ្ងៃសវនាការ តាមការកោះអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជា ចំនួន ០៥ ចំណុចនេះបន្ថែមទៀត ប៉ុន្តែនៅតែមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។

នៅក្នុងសំណុំរឿងនេះ ក្រុមហ៊ុន វីកកូ គឺជាសមាជិកនៃសមាគមរោងចក្រកាត់ដេរកម្ពុជា ដែលជាភាគីហត្ថលេខីនៃអនុស្សារណៈនៃការយោគយល់គ្នា ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១២ ស្តីពីការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈនៅក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់។ ចំណែកឯសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ក៏ជាភាគីហត្ថលេខីនៃអនុស្សារណៈនៃការយោគយល់គ្នានេះដែរ។ សហជីពសេរីកម្មករប្រចាំក្រុមហ៊ុន វីកកូ កំពុងត្រូវបានរៀបចំឡើង ប៉ុន្តែមិនទាន់ទទួលបានចុះបញ្ជិកាសហជីពនៅឡើយទេ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សហជីពសេរីកម្មករប្រចាំក្រុមហ៊ុន វីកកូ មិនទាន់ក្លាយជាអង្គការវិជ្ជាជីវៈ ស្របតាមច្បាប់ស្តីពីការងារទេ។

ក្នុងករណីនេះ ថ្វីត្បិតតែសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុន វីកកូ ជាភាគីហត្ថលេខីនៃអនុស្សារណៈនៃការយោគយល់គ្នា ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១២ ក៏ដោយ ប៉ុន្តែដោយសារសហជីពសេរីកម្មករប្រចាំក្រុមហ៊ុន វីកកូ មិនទាន់ទទួលឋានៈជាអង្គការវិជ្ជាជីវៈ ស្របតាមច្បាប់ស្តីពីការងារ ព្រោះមិនទាន់ត្រូវបានចុះបញ្ជិកាជាផ្លូវការនៅឡើយ ហេតុនេះ ការដែលបុគ្គលិកសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា បានមកចូលរួមសវនាការ មិនអាចបកស្រាយថា គូភាគីនៃសំណុំរឿងនេះ គឺជាហត្ថលេខីនៃអនុស្សារណៈស្តីពីការយោគយល់គ្នា ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១២ បានឡើយ។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានកំណត់ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤ ជាថ្ងៃផុតកំណត់នៃការដាក់ភស្តុតាង ជាពិសេស លិខិតផ្ទេរសិទ្ធិតំណាងឱ្យភាគីក្នុងសវនាការ និងលិខិតបញ្ជាក់ច្បាស់អំពីការពឹងពាក់របស់កម្មករនិយោជិតពាក់ព័ន្ធឱ្យសហជីពតំណាងក្នុងសវនាការ និងថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៤ ជាថ្ងៃផុតកំណត់នៃការជំទាស់ភស្តុតាង។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិរបស់នាយកសហគ្រាស វីកកូ ហៃនប៉ែក (ខេមបូឌា) ផ្ទេរសិទ្ធិតំណាងឱ្យក្រុមហ៊ុន ក្នុងសវនាការ ជូនលោក ជា សុខទ្រី និងលោកស្រី អ៊ុំ ណារី ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤។

២- លិខិតទំនាក់ទំនងផ្ទៃក្នុងជូនដំណឹងទៅ គាត់ គឹមឈិន ពីការផុតកំណត់កិច្ចសន្យា។

៣- កិច្ចសន្យាការងារមានថេរវេលាកំណត់សំរាប់កម្មករនិយោជិតពេញសិទ្ធិ របស់ឈ្មោះ គាត់ គឹមឈិន ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣។

៤- តារាងបៀវត្សប្រចាំខែ១ ដល់ខែ ១១ ឆ្នាំ២០១៣។

៥- តារាងបៀវត្សប្រចាំខែ៩ ដល់ខែ ១២ ឆ្នាំ២០១២។

៦- តារាងប្រាក់បំណាច់ឆ្នាំ គិតចាប់ពីឆ្នាំ០១/០៩/១២ ដល់ ៣០/០៩/១៣។

៧- តារាងឈ្មោះកម្មករនិយោជិតដែលត្រូវបើក ៥ % ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣។

៨- តារាងឈ្មោះកម្មករនិយោជិតដែលត្រូវបើក ៥ % ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣។

៩- តារាងឈ្មោះកម្មករនិយោជិតដែលត្រូវបើក ៥ % ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៣។

១០- តារាងឈ្មោះកម្មករនិយោជិតដែលត្រូវបើក ៥ % ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៣។

១១- តារាងឈ្មោះកម្មករនិយោជិតដែលត្រូវបើក ៥ % ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៣។

១២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន វីកកូ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤។

១៣- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម លេខ ២២៤៩ ពណ.ចបព ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១២។

១៤- លក្ខន្តិកៈក្រុមហ៊ុន វីកកូ ហៃនប៉ែក (ខេមបូឌា) បានតំកល់ទុកនៅនាយកដ្ឋាននីតិកម្ម និងច្បាប់វិនិយោគ យោងតាមលិខិតលេខ ៦២២/១២គវក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១២។

១៥- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន វីកកូ ហៃនប៉ែក បានចុះទិដ្ឋាការលេខ ៦៣៦/១៣ កបវ.កស្ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៣ ដោយប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមក្រុមហ៊ុន វីកកូ ហៃនប៉ែក ខេមបូឌា អិនដាសស្ទ្រៀល លេខ ០៨២/១៤ របក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤។

២- កំណត់ស្ដីពីការផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន វីកកូ ហ៊ែនប៉ែក ខេមបូឌា អ៊ិនដាសស្ទ្រៀល ចុះថ្ងៃទី ៣០ ខែមករា ឆ្នាំ ២០១៤។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ១៥២ កប/អក/វក/លកអ. ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៤ ។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ១៥៣ កប/អក/វក/លកអ. ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៤។

៣- កិច្ចព្រមព្រៀងយកសេចក្ដីបង្គាប់ជាប់កាតព្វកិច្ចលើចំណុចវិវាទទាំងអស់ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ដែលចុះហត្ថលេខាដោយតំណាងនិយោជក និងលោក ឃុត ថេត។

**អង្គហេតុ ÷**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្ដាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងភាគីនិយោជក
- ក្រោយពីបានពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា ៖

- ក្រុមហ៊ុន វីកកូ ហ៊ែនប៉ែក (ខាមបូឌា) អ៊ិនដាសស្ទ្រៀល (តទៅនេះហៅថា "ក្រុមហ៊ុន វីកកូ") គឺជាក្រុមហ៊ុន ដែលមានសកម្មភាពចំបងក្នុងការផលិតកាបូបគ្រប់ប្រភេទ ដែលបានចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Inv.០៨៩២E/២០១២ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១២។ នាថ្ងៃសវនាការ ភាគីនិយោជកបានបញ្ជាក់ថា ក្រុមហ៊ុននេះ បានចាប់ផ្ដើមដំណើរការពីខែកក្កដា ឆ្នាំ២០១២ ហើយនាពេលបច្ចុប្បន្ន ក្រុមហ៊ុនមានជួលកម្មករនិយោជិតសរុបប្រមាណជា ១៤៨២ នាក់។
- សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា គឺជាអ្នកដាក់ពាក្យបណ្ដឹងនៅក្នុងសំណុំរឿងនេះ។
- សហជីពសេរីកម្មករប្រចាំក្រុមហ៊ុន វីកកូ បានបោះឆ្នោតបង្កើតសហជីពនៅក្នុងខែមករា ឆ្នាំ២០១៤ ដែលជាលទ្ធផល កម្មករ តាត់ គីមឈិន ជាប់ឆ្នោតជាប្រធានសហជីព។ ភាគីកម្មករនិយោជិតបានបញ្ជាក់ថា សហជីពនេះ មិនទាន់ទទួលបានបញ្ជិកាសហជីពទេ។
- បុគ្គលដែលមកចូលរួមសវនាការអាជ្ញាកណ្ដាលនៃសំណុំរឿងលេខ ២១/១៤ - វីកកូ ហ៊ែនប៉ែក ខាមបូឌា នាថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ រួមមាន ៖
  - តំណាងភាគីនិយោជក ៖
    - អ្នកស្រី អ៊ុំ ណាវី ជាប្រធានរដ្ឋបាល
    - លោក ជា សុខទ្រី ជារដ្ឋបាល
  - បុគ្គលដែលអះអាងថា ជាតំណាងភាគីកម្មករនិយោជិត ៖

THE ARBITRATION COUNCIL

- លោក ឃុត ថេត ជាបុគ្គលិកសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា
- កម្មករ គាត់ គីមឈិន ជាកម្មករនិយោជិតនៃក្រុមហ៊ុន វីកកូ

- ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលនូវលិខិតពឹងពាក់របស់កម្មករនិយោជិតមួយចំនួនមិនច្បាស់លាស់ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៤ ដែលពឹងពាក់លោក ជា មុនី ប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ឱ្យជួយដោះស្រាយបញ្ហាទាមទារទាំង ០៥ ចំណុច ដែលមានភ្ជាប់មកជាមួយនឹងរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមលេខ ០៨២/១៤ របក។ ទោះជាយ៉ាងនេះក៏ដោយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិនិត្យឃើញថា លិខិតពឹងពាក់នេះ មានភាពមិនច្បាស់លាស់ មិនអាចយកជាការបានឡើយ ដោយសារ ៖
  - ទំព័រទី ០១ នៃលិខិតនេះ មានចំនងជើងបញ្ជាក់ថា ជាលិខិតពឹងពាក់របស់កម្មករ-កម្មការិនី នៃក្រុមហ៊ុន វីកកូ ចូលមកលោក ជា មុនី ប្រធានសហជីពសេរីកម្មករ មានឈ្មោះរបស់កម្មករនិយោជិត ប៉ុន្តែមិនមានស្នាមមេដៃច្បាស់លាស់របស់ កម្មករនិយោជិតដែលមានឈ្មោះនៅលើទំព័រទី ០១ នោះឡើយ ។
  - ចំណែកឯទំព័រទី ០២ និងទី ០៣ មានតែឈ្មោះរបស់កម្មករនិយោជិតប៉ុណ្ណោះ ដោយមិនមានបញ្ជាក់ថា ជាកម្មករនិយោជិតរបស់ក្រុមហ៊ុនណា មិនមានចំនងជើងបញ្ជាក់ថា ជាលិខិតពឹងពាក់ ឬយ៉ាងណា ហើយមិនមានស្នាមមេដៃច្បាស់លាស់របស់កម្មករនិយោជិតទាំងនោះឡើយ ។
  - រីឯទំព័រទី ០៤ វិញ មានឈ្មោះ និងស្នាមមេដៃរបស់កម្មករនិយោជិត ប៉ុន្តែមិនមានការបញ្ជាក់ថាពួកគាត់ជាកម្មករនិយោជិតរបស់ក្រុមហ៊ុនណា និងមិនមានចំនងជើងបញ្ជាក់ថា ជាលិខិតពឹងពាក់ ឬ ផ្ទេរសិទ្ធិ របស់ពួកគាត់ ជូនសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើការទាមទារឡើយ ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លិខិតពឹងពាក់នេះ មិនមានភាពច្បាស់លាស់ គ្រប់គ្រាន់ក្នុងការបង្ហាញថា វាជាលិខិតផ្ទេរសិទ្ធិរបស់កម្មករនិយោជិតពាក់ព័ន្ធនៃក្រុមហ៊ុន វីកកូ ជូនសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើជាតំណាងក្នុងការទាមទារនៅក្នុងសំណុំរឿងនេះឡើយ ។

- នៅក្នុងសវនាការលើសំណុំរឿងលេខ ២១/១៤ - វីកកូ ហ៊ែនប៊ែក ខាមបូឌា នាថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ គ្មានលិខិតផ្ទេរសិទ្ធិឱ្យធ្វើជាអ្នកតំណាងណាមួយ ត្រូវបានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានពន្យល់អំពីសារៈសំខាន់ និងភាពចាំបាច់តាមផ្លូវច្បាប់របស់លិខិតផ្ទេរសិទ្ធិជូនភាគីទាំងឡាយដែលមានវត្តមានក្នុងសវនាការ និងតម្រូវយ៉ាងដាក់លាក់ ឱ្យភាគីពាក់ព័ន្ធដាក់ជូន នូវលិខិតផ្ទេរសិទ្ធិដែលមានភាពត្រឹមត្រូវ និងច្បាស់លាស់អាចយកជាបានការ ឱ្យធ្វើជាអ្នកតំណាង យ៉ាងយូរត្រឹមម៉ោង ០៥៖០០ ល្ងាច នៃថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤ ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ដល់ពេលផុតកំណត់នេះ មានតែភាគីនិយោជកប៉ុណ្ណោះ ដែលបានផ្តល់លិខិតផ្ទេរសិទ្ធិជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ចំណែកឯសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជាដែលអះអាងថា ខ្លួនតំណាងឱ្យកម្មករនិយោជិតពាក់ព័ន្ធ

ក្នុងសំណុំរឿងនេះ មិនបានផ្តល់លិខិតផ្ទេរសិទ្ធិ ដើម្បីបញ្ជាក់ថា កម្មករនិយោជិតពាក់ព័ន្ធនៃក្រុមហ៊ុន វីកកូ ពិតជាបានផ្ទេរសិទ្ធិជូនសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ឱ្យធ្វើជាអ្នកតំណាងក្នុងសវនាការ ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។ លើសពីនេះ លោក ឃុត ថេត ជាបុគ្គលិកសហជីព សេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ដែលបានចូលរួមក្នុងសវនាការតាមការអនុញ្ញាតជាបណ្តោះអាសន្ន របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក៏មិនបានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល នូវឯកសារបង្ហាញអំពីសិទ្ធិរបស់ខ្លួន ក្នុងការតំណាងឱ្យលោក ជា មុនី ប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជាឡើយ។ បន្ថែមពីលើនេះ កម្មករ គាត់ គីមឈិន ក៏មិនបានផ្តល់នូវលិខិតផ្ទេរសិទ្ធិណាមួយ ដែលបានបញ្ជាក់ថា កម្មករនិយោជិតពាក់ព័ន្ធនៃក្រុមហ៊ុន វីកកូ បានផ្ទេរសិទ្ធិជូនគាត់ ដើម្បីធ្វើការទាមទារនៅក្នុងសំណុំរឿងនេះដែរ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

**ជាបឋម ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាលើសមាសភាពរបស់តំណាងភាគីកម្មករនិយោជិត ដែលបានមកចូលរួមសវនាការអាជ្ញាកណ្តាល នៅក្នុងសំណុំរឿងលេខ ២១/១៤ - វីកកូ ហ៊ោនប៊ែក ខាមបូឌា នាថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០១៤ ជាមុនសិន។**

- <u>លោក ឃុត ថេត ជាបុគ្គលិកសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា</u>

ប្រការ ១៩ នៃប្រកាសលេខ ៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២004 ចែងថា ៖ *"ភាគីវិវាទអាចមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម ឬអ្នកតំណាងដោយមេធាវី ដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬដោយបុគ្គលផ្សេងទៀត ដែលទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ"*។

យោងតាមប្រការ១៩ នៃប្រកាសលេខ ០៩៩/០៤ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ពាក្យថា *"ទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរ"* មានន័យថា ភាគីវិវាទអាចឱ្យបុគ្គលផ្សេងតំណាងឱ្យខ្លួនក្នុងការដោះស្រាយវិវាទការងារនៅចំពោះមុខក្រុមអាជ្ញាកណ្តាលបាន លុះត្រាតែបុគ្គលនោះទទួលបានការអនុញ្ញាត ជាលាយលក្ខណ៍អក្សរ ដើម្បីមកធ្វើជាតំណាងរបស់ភាគីវិវាទ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១៦១/០៩-សិប្បកម្ម ព្រែកត្រែង, លេខ ៤៣/១០-ម៉ឹង ជៀន និងលេខ ១៤៤/១២-អ៊ី ហ្គាមេទ)*។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលនូវលិខិតពឹងពាក់របស់កម្មករនិយោជិតមួយចំនួន មិនច្បាស់លាស់ (លិខិតចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៤ ជូនលោក ជា មុនី ប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជួយដោះស្រាយបញ្ហាមួយចំនួន) ដែលមានភ្ជាប់មកជាមួយនឹងរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម លេខ ០៨២/១៤ របក។ ទោះជាយ៉ាងនេះក៏ដោយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិនិត្យឃើញថា លិខិតពឹងពាក់នេះមិនមានភាពត្រឹមត្រូវ និងច្បាស់លាស់គ្រប់គ្រាន់ ក្នុងការបញ្ជាក់ថា នេះពិតជាលិខិតផ្ទេរសិទ្ធិរបស់កម្មករនិយោជិតពាក់ព័ន្ធទាំងឡាយណានៃក្រុមហ៊ុន វីកកូ ជូនសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើការទាមទារ និងតំណាងឱ្យភាគីកម្មករនិយោជិតនៅក្នុងសំណុំរឿងនេះឡើយ។

តាមអង្គហេតុខាងលើនេះ ទោះជាក្រុមប្រឹក្សាអាជ្ញាកណ្តាលបានពន្យល់អំពីភាពមិនច្បាស់លាស់នៃលិខិតពឹងពាក់ និងអំពីសារៈសំខាន់ និងភាពចាំបាច់តាមផ្លូវច្បាប់របស់លិខិតផ្ទេរសិទ្ធិ និងបានបង្គាប់ឱ្យភាគីផ្តល់នូវលិខិតផ្ទេរសិទ្ធិត្រឹមត្រូវ និងច្បាស់លាស់យកជាការបាន ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រឹមកាលកំណត់នៃការអនុញ្ញាតឱ្យដាក់ភស្តុតាងចាំបាច់ក្រោយសវនាការក៏ដោយ សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា មិនបានផ្តល់លិខិតផ្ទេរសិទ្ធិដែលបញ្ជាក់ថាកម្មករនិយោជិតណាខ្លះនៃក្រុមហ៊ុន វីកកូ បានផ្ទេរសិទ្ធិជូនសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើការទាមទារ និងតំណាងនៅក្នុងសវនាការអាជ្ញាកណ្តាលសម្រាប់សំណុំរឿងនេះ ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា បុគ្គលិកសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ដែលបានមកចូលរួមសវនាការអាជ្ញាកណ្តាលនៃសំណុំរឿងលេខ ២១/១៤ - វីកកូ ហៃនប៊ែក ខាមបូឌា នាថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ មិនមានសិទ្ធិស្របច្បាប់ក្នុងការតំណាងឱ្យកម្មករនិយោជិតពាក់ព័ន្ធ នៃក្រុមហ៊ុន វីកកូ ដើម្បីធ្វើការទាមទារ និងតំណាងនៅក្នុងសវនាការអាជ្ញាកណ្តាលសម្រាប់សំណុំរឿងនេះទេ ។

- <u>កម្មករ គាត់ គីមឈិន ជាអតីតកម្មករនៃក្រុមហ៊ុន វីកកូ</u>

មាត្រា ២៦៨ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ចែងថា ៖ *"ដើម្បីឱ្យអង្គការវិជ្ជាជីវៈទទួលបាននូវសិទ្ធិ និងផលប្រយោជន៍ទាំងឡាយដែលច្បាប់ការងារនេះទទួលស្គាល់ ស្ថាបនិកនៃអង្គការវិជ្ជាជីវៈទាំងនោះត្រូវយកលក្ខន្តិកៈ និងបញ្ជីរាយនាមនៃអ្នកទទួលខុសត្រូវក្នុងការដឹកនាំ និងកិច្ចការរដ្ឋបាល ទៅតំកល់ទុកនៅក្រសួងទទួលបន្ទុកវិស័យការងារ ដើម្បីសុំចុះបញ្ជិកា ។..."*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រា ២៦៨ នៃច្បាប់ស្តីពីការងារខាងលើនេះមានន័យថា អង្គការវិជ្ជាជីវៈទទួលបាននូវសិទ្ធិ និងផលប្រយោជន៍ទាំងឡាយដែលច្បាប់ស្តីពីការងារទទួលស្គាល់ នៅពេលដែលអង្គការវិជ្ជាជីវៈ បានចុះបញ្ជិកានៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងបញ្ជីរាយរាមនៃអ្នកទទួលខុសត្រូវក្នុងការដឹកនាំ ត្រូវបានទទួលស្គាល់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

នៅក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ឃើញដែរថា សិទ្ធិ និងផលប្រយោជន៍នេះ រួមបញ្ចូលទាំងសិទ្ធិរបស់សហជីពក្នុងការតំណាងសមាជិករបស់ខ្លួន មកដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៦២/០៦-ឃ្វីកស្វ៊ី ហេតុផលចំណុចវិវាទទី២,លេខ ៣០/០៨-អ៊ីហ្គាមេន, លេខ ៣១/០៨-សៅធន៍បើរ និងលេខ ៩៤/០៩-គាកហ្វាត)* ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងសំណុំរឿងមុនៗដែរ ។

ក្នុងករណីនេះ ភាគីកម្មករនិយោជិតបានបញ្ជាក់នៅក្នុងសវនាការថា សហជីពសេរីកម្មករនៃក្រុមហ៊ុន វីកកូ មិនទាន់ទទួលបានបញ្ជិកាសហជីពទេ ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិនិត្យឃើញថា សហជីពសេរីកម្មករនៃក្រុមហ៊ុន វីកកូ មិនទាន់ក្លាយជាអង្គការវិជ្ជាជីវៈ ដែលទទួលបាននូវសិទ្ធិ និងផលប្រយោជន៍ទាំងឡាយដែលច្បាប់ស្តីពីការងារទទួលស្គាល់ឡើយ ។ ហេតុនេះ កម្មករ គាត់ គីមឈិន ដែលជាបេក្ខជនជាប់ឆ្នោតជាប្រធានសហជីព មិនទាន់

ក្លាយថ្នាក់ដឹកនាំស្របច្បាប់របស់សហជីពសេរីកម្មករនៃក្រុមហ៊ុន វីកកូ ទេ។ ដូចនេះ គាត់មិនមានសិទ្ធិស្របច្បាប់តំណាងឱ្យសមាជិករបស់ខ្លួន ដែលជាកម្មករនិយោជិតពាក់ព័ន្ធនៃក្រុមហ៊ុន វីកកូ ទេ។

លើសពីនេះ កម្មករ គាត់ គីមឈិន ក៏មិនបានផ្តល់នូវលិខិតផ្ទេរសិទ្ធិណាមួយ ដែលបានបញ្ជាក់ថា កម្មករនិយោជិតនៃក្រុមហ៊ុន វីកកូ បានផ្ទេរសិទ្ធិជូនគាត់ ដើម្បីធ្វើការទាមទារនៅក្នុងសំណុំរឿងនេះដែរ។ ហេតុដូចនេះ ផ្អែកតាមប្រការ១៩ នៃប្រកាសលេខ ៩៩/០៤ ខាងលើ កម្មករ គាត់ គីមឈិន មិនមានសិទ្ធិស្របច្បាប់ក្នុងការតំណាងឱ្យកម្មករនិយោជិតពាក់ព័ន្ធនៃក្រុមហ៊ុន វីកកូ ដើម្បីធ្វើការទាមទារ និងតំណាងនៅក្នុងសវនាការអាជ្ញាកណ្តាលសម្រាប់សំណុំរឿងនេះទេ។

ទោះជាយ៉ាងនេះក៏ដោយ កម្មករ គាត់ គីមឈិន ជាកម្មករតែមួយរូបគត់ ដែលបង្ហាញថា ពាក់ព័ន្ធ និងទាមទារក្នុងសំណុំរឿងនេះ បានចូលរួមផ្ទាល់ក្នុងសវនាការអាជ្ញាកណ្តាលនៃសំណុំរឿងនេះ។ ដូចនេះ ផ្អែកតាមប្រការ ១៩ នៃប្រកាសលេខ ៩៩/០៤ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិនិត្យឃើញថា កម្មករ គាត់ គីមឈិន គឺជាភាគីដើមបណ្តឹងតែម្នាក់គត់នៅក្នុងសំណុំរឿងនេះ។

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាថា តើក្រុមប្រឹក្សាអាជ្ញាកណ្តាលមានយុត្តាធិការ ក្នុងការសម្រេចសេចក្តីនៅក្នុងសំណុំរឿងលេខ ២១/១៤ - វីកកូ ហ៊ែនវ៉ែក ខាមបូឌា នេះ ដែរ ឬទេ?**

ប្រការ ៣២ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលចែងថា ៖ *"ក្រុមអាជ្ញាកណ្តាលត្រូវសម្រេចសេចក្តីលើវិវាទការងាររួមដែលដាក់មកខ្លួនដោយយោងទៅតាមមាត្រា ៣០៩ នៃច្បាប់ស្តីពីការងារ ។"*

តាមរយៈប្រការនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានយុត្តាធិការដោះស្រាយតែវិវាទការងាររួមប៉ុណ្ណោះ។

បន្ថែមពីលើនេះ ដោយអនុលោមទៅតាមជំពូក១២ ផ្នែកទី២ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ក្រុមប្រឹក្សាអាជ្ញាកណ្តាល មានយុត្តាធិការក្នុងការសម្រេចតែលើវិវាទការងាររួមតែប៉ុណ្ណោះ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៩៤/០៤-អេ អាយ អេ ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៦, លេខ៨១/០៦-ហុង អ៊ី ហេតុផលនៃសេចក្តីសម្រេចចំណុច វិវាទ ទី១)*។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សេចក្តីបង្គាប់ពីមុនៗរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក៏បានបកស្រាយអំពីយុត្តាធិការរបស់ខ្លួនស្របតាមខ្លឹមសារនៃច្បាប់ស្តីពីការងារ និងប្រកាសដែលបានយោងខាងលើនេះដែរ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញា កណ្តាលនៅក្នុងសំណុំរឿងមុនៗដែរ។

មាត្រា ៣០២ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ចែងថា ៖ *"វិវាទការងាររួម គឺជាវិវាទដែលកើតឡើងរវាងនិយោជកម្នាក់ ឬច្រើននាក់ នឹងបុគ្គលិករបស់ខ្លួនមួយចំនួន អំពីរឿងល័ក្ខខ័ណ្ឌការងារ ការប្រើប្រាស់សិទ្ធិដែលប្រគល់ឱ្យអង្គការវិជ្ជាជីវៈ ការត្រូវទទួលស្គាល់អង្គការវិជ្ជាជីវៈក្នុងសហគ្រាស បញ្ហានៃការទាក់ទងរវាងនិយោជក និងកម្មករនិយោជិត ហើយការវិវាទនេះអាចបណ្តាលឱ្យសហគ្រាសប្រព្រឹត្តទៅពុំបានស្រួល ឬធ្វើឱ្យខូចសន្តិភាពសង្គម ។"*

នៅក្នុងសំណុំរឿងលេខ ១០/០៣-ហ្សាក់ស៊ីនតិច ក្រុមប្រឹក្សាអាជ្ញាកណ្តាលបញ្ជាក់ថា ៖ *"ដើម្បីអាចនិយាយបានថា វិវាទមួយជាវិវាទរួម ត្រូវបំពេញជាចាំបាច់តាមលក្ខខណ្ឌវិនិច្ឆ័យបីយ៉ាងនៃវិវាទការងាររួម ដូចមានចែងក្នុងច្បាប់ស្តីពីការងារមាត្រា ៣០២ ។ លក្ខខណ្ឌវិនិច្ឆ័យបីយ៉ាងនោះគឺ ៖*

*ក- ជាវិវាទរវាងកម្មករមួយចំនួន និងនិយោជកម្នាក់ ឬច្រើននាក់*

*ខ- បញ្ហានៃវិវាទទាក់ទងនឹងលក្ខខណ្ឌការងារ ការប្រើប្រាស់សិទ្ធិ ដែលប្រគល់ឱ្យអង្គការវិជ្ជាជីវៈ ទទួលស្គាល់អង្គការវិជ្ជាជីវៈ ឬបញ្ហានៃទំនាក់ទំនងរវាងនិយោជក និងកម្មករនិយោជិត*

*គ- វិវាទនេះ អាចបណ្តាលឱ្យសហគ្រាសប្រព្រឹត្តទៅពុំបានស្រួល ឬធ្វើឱ្យខូចសន្តិភាពសង្គម"* ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយបញ្ជាក់អំពីលក្ខខណ្ឌវិនិច្ឆ័យនៃវិវាទការងាររួម ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលបានពិភាក្សានៅក្នុងសំណុំរឿងមុននេះដែរ ។ ពោលគឺ លក្ខខណ្ឌវិនិច្ឆ័យទាំង ០៣ ត្រូវតែបានបំពេញទាំងអស់ដើម្បីឱ្យវិវាទមួយក្លាយជាវិវាទការងាររួម ។

តាមរយៈការបកស្រាយខាងលើ មានតែកម្មករ គាត់ គឹមឈិន មួយរូបគត់ គឺជាភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងលេខ ២១/១៤ - វីកកូ ហ៊ែនប៊ែក ខាមបូឌា និងដែលបានមកចូលរួមសវនាការអាជ្ញាកណ្តាលនៃសំណុំរឿងនេះ នាថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលវិភាគឃើញថា ដោយសារកម្មករនិយោជិតដែលធ្វើការទាមទារនៅក្នុងសំណុំរឿងនេះ មានតែ ០១ រូបប៉ុណ្ណោះ ហេតុនេះ លក្ខខណ្ឌវិនិច្ឆ័យចំនុច "ក" នៃវិវាទការងាររួមមិនត្រូវបានបំពេញទេ ។ ដោយសារលក្ខខណ្ឌវិនិច្ឆ័យ "ក" មិនត្រូវបានបំពេញ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនចាំបាច់បន្តពិចារណាលើលក្ខខណ្ឌវិនិច្ឆ័យចំនុច "ខ" និង "គ" ទៀតទេ ។ ក្នុងករណីនេះ សំណុំរឿងនេះទាំងមូល មិនមែនជាសំណុំរឿងនៃវិវាទការងាររួមទេ ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនមានយុត្តាធិការក្នុងការសម្រេចសេចក្តី លើសំណុំរឿងលេខ ២១/១៤ - វីកកូ ហ៊ែនប៊ែក ខាមបូឌា នេះទេ ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធនូវការពិចារណាលើការទាមទាររបស់ភាគីកម្មករនិយោជិត នៅក្នុងសំណុំរឿងលេខ ២១/១៤ - វីកកូ ហ៊ែនប៊ែក ខាមបូឌា នេះ ។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផលដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

បដិសេធនូវការពិចារណាលើការទាមទាររបស់ភាគីកម្មករនិយោជិត នៅក្នុងសំណុំរឿងលេខ ២១/១៤ វីកកូ ហ៊ែនប៊ែក ខាមបូឌា ។

THE ARBITRATION COUNCIL

ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច

*សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍ អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក

ឈ្មោះ ៖ **អ៊ឹុង សុទ្ធី**

ហត្ថលេខា ៖ ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖ ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល

ឈ្មោះ ៖ **ញ៉ាន សុមុន្និន្ទ**

ហត្ថលេខា ៖ ------------------------------